# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២៨៥ សហវ.ប្រក.ហម

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០១២

Adm & F.D.

# ប្រកាស
## ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាចវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

គាត់ ចំរើន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញប្រកាសលេខ ២០៣ ប្រក សហវ.ថ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ជាថវិកាខេត្ត ក្រុង
- ប្រកាសលេខ ៣២៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០២ ស្តីពីទម្រង់និងមាតិកាថវិកាឃុំ សង្កាត់ និងត្រូវបានកែសម្រួលដោយប្រកាសលេខ ៨៨១ សហវ.ហម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៣ និងប្រកាសលេខ ២០២ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួល និងបំពេញបន្ថែមនូវគំរូតារាងរបាយការណ៍ មាតិកាថវិកា មាតិកាគណនីឃុំ សង្កាត់
- បានឃើញប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញប្រកាសលេខ ១៤០៩ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត ក្រុង និងស្រុក ខណ្ឌ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** ត្រូវបានដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលចែកជាចំណាត់ថ្នាក់ចំណូល ចំណាយ និងត្រូវបានបែងចែកជាក្រុម ប្រភេទ ជំពូក គណនី និងអនុគណនីដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣:** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ តទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់

<u>ចម្លងជូន:</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ក្រសួងមហាផ្ទៃ

"ដើម្បីសហការ"
- អគ្គនាយកដ្ឋានរតនាគារជាតិ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- សាខាពន្ធដាររាជធានី ខេត្ត
- រដ្ឋបាលថ្នាក់ក្រោមជាតិ

"ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## មាតិកាចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ផ្សេងៗ |
|---|---|---|---|---|
| **សរុបរួមចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (I + II)** | | | | |
| **I - សរុបចំណូលចរន្ត (ក + ខ)** | | | | |
| **ក. ក្រុមទី ១ : ចំណូលពិត (ប្រ.១ + ប្រ.២)** | | | | |
| **ប្រភេទទី ១: ចំណូលសារពើពន្ធ** | | | | |
| **70** | | | ចំណូលសារពើពន្ធ | |
| | 701 | | ពន្ធលើបេតិកភ័ណ្ឌ | |
| | | 7011 | ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរមរតករវាងអ្នកនៅរស់ | |
| | | 7012 | ពន្ធប្រថាប់ត្រា-ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | |
| | | 7013 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | |
| | 702 | | ពន្ធលើទ្រព្យសម្បត្តិដែលបានកំណត់ | |
| | | 7021 | អាករសម្រាប់បំភ្លឺសាធារណៈ | |
| | 703 | | ពន្ធលើសេវាដែលបានកំណត់ | |
| | | 7031 | អាករលើការស្នាក់នៅ | |
| | | 7032 | ពន្ធសត្តឃាត | |
| | 704 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព | |
| | | 7041 | ពន្ធប៉ាតង់ | |
| | | 7042 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ | |
| | 707 | | ពន្ធលើអចលនទ្រព្យ | |
| | | 7071 | ពន្ធលើអចលទ្រព្យរូបវន្តបុគ្គល | |
| | | 7072 | ពន្ធលើអចលទ្រព្យនីតិបុគ្គល | |
| **ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ** | | | | |
| **72** | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | |
| | 721 | | ផលនៃការជួលដីធ្លី | |
| | | 7211 | សម្បទានពីរ៉ែ | |
| | | 7212 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | |
| | | 7213 | ចំណូលពីចំណតរថយន្ត | |
| | | 7214 | ចំណូលពីចំណតជលយាន | |
| **73** | | | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា | |
| | 731 | | សហគ្រាសសាធារណៈ-រដ្ឋបាល និងសេវាទ្រព្យសម្បត្តិ | |
| | 732 | | ផលពីការគ្រប់គ្រងរដ្ឋបាល | |
| | | 7321 | សេវាសុរិយោដី | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ផ្សេងៗ |
|---|---|---|---|---|
| | | 7322 | សេវាសំណង់ | |
| | | 7323 | ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល | |
| | | 7324 | ចំណូលពីការអនុញ្ញាតរដ្ឋបាល | |
| | | 7325 | សេវាត្រួតពិនិត្យអនាម័យសត្វនៅសត្តឃាតដ្ឋាន | |
| | | 7328 | ចំណូលរដ្ឋបាលផ្សេងៗទៀត | |
| | 733 | | ការជួលទ្រព្យសម្បត្តិអចល័ត | |
| | | 7331 | ចំណូលពីសត្តឃាតដ្ឋាន | |
| | | 7332 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | |
| | | 7333 | ចំណូលពីកំពង់ចម្លង | |
| | | 7334 | ចំណូលពីឃ្លាំត្រីនិងពីកន្លែងបែងចែកផលិតផល | |
| | | 7335 | ចំណូលពីភាស៊ីផ្សារ | |
| | | 7338 | ការជួលទ្រព្យសម្បត្តិអចល័តផ្សេងៗទៀត | |
| **74** | | | **ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម** | |
| | 741 | | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | |
| | 742 | | ផលពីការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធគយ | |
| **75** | | | **ការឧបត្ថម្ភកធន** | |
| | 751 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | |
| | 752 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិការាជធានី ខេត្ត | |
| | 753 | | ទាយជ្ជទានសម្រាប់ដំណើរការដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ | |
| | 754 | | ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន | |
| | 755 | | ការចូលរួមធនធានពីដៃគូអភិវឌ្ឍ | |
| | 756 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | |
| | | 7561 | ពីក្រសួង ស្ថាប័ន | |
| | | 7562 | ពីមន្ទីរជំនាញ | |
| | | 7563 | ពីរាជធានី ខេត្ត | |
| | | 7564 | ពីក្រុង ស្រុក ខណ្ឌ | |
| | 758 | | ចំណូលឧបត្ថម្ភពីប្រភពផ្សេងៗ | |
| **76** | | | **ផលហិរញ្ញវត្ថុ** | |
| | 768 | | ផលហិរញ្ញវត្ថុផ្សេងទៀត | |
| **77** | | | **ផលផ្សេងៗ និងផលពិសេស** | |
| | 775 | | ផលពីការលក់អចលកម្ម | |
| **ខ. ក្រុមទី ២ : ចំណូលតាមដីកា** (ប្រ.៣) | | | | |
| **ប្រភេទទី ៣: ចំណូលតាមដីកា** (**មិនឆ្លងកាត់សាច់ប្រាក់**) | | | | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | ផ្សេងៗ |
|---|---|---|---|---|
| 78 | | | ការងារនៃរដ្ឋទេយ្យ | |
| II - សរុបចំណូលជាមូលធន ( ក + ខ ) | | | | |
| ក. ក្រុមទី ១: ចំណូលពិត ( ប្រ.១ + ប្រ.២ ) | | | | |
| ប្រភេទទី ១: ឧបត្ថម្ភកធន | | | | |
| 08 | | | ចំណូលមូលនិធិបម្រុង | |
| 13 | | | ឧបត្ថម្ភកធន - វិនិយោគ | |
| | 131 | | ឧបត្ថម្ភកធនទទួលសម្ភារៈបរិក្ខារទ្វេភាគី | |
| | 132 | | ទាយជ្ជទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ | |
| | 133 | | ទាយជ្ជទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិការាជធានី ខេត្ត | |
| | 134 | | ទាយជ្ជទានសម្រាប់វិនិយោគដែលឧបត្ថម្ភពីថវិកាក្រុង ស្រុក ខណ្ឌ | |
| | 135 | | ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង | |
| | 136 | | ការចូលរួមធនធានពីដៃគូអភិវឌ្ឍ | |
| | 138 | | ចំណូលមូលធនពីប្រភពផ្សេងៗ | |
| ប្រភេទទី ២: ចំណូលតាមដីកា ( មិនឆ្លងកាត់សាច់ប្រាក់ ) | | | | |

# ឧបសម្ព័ន្ធ២

## មាតិកាចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| **សរុបរួមឥណទានថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (I + II)** | | | | |
| **I - សរុបចំណាយចរន្ត ( ក + ខ )** | | | | |
| **ក. ក្រុមទី ១: ចំណាយពិត** ( ប្រ.១+ប្រ.២+ប្រ.៣+ប្រ.៤ ) | | | | |
| **ប្រភេទទី ១: មធ្យោបាយសេវា** | | | | |
| 60 | | | ការទិញ | |
| | 601 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | |
| | | 6011 | សម្ភារៈផ្គត់ផ្គង់សំអាត និងអនាម័យ | |
| | | 6012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ | |
| | | 6013 | សម្ភារៈផ្គត់ផ្គង់សម្រាប់ជួសជុលផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ | |
| | | 6014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | |
| | | 6015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | |
| | 602 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | |
| | | 6021 | សម្ភារៈការិយាល័យ និងការបោះពុម្ព | |
| | | 6022 | សៀវភៅមើល និងឯកសារ | |
| | | 6028 | ផ្សេងៗ | |
| | 603 | | ស្បៀងអាហារ | |
| | | 6031 | ស្បៀង | |
| | 604 | | សំលៀកបំពាក់ និងការតុបតែង | |
| | | 6041 | ឯកសណ្ឋាន | |
| | | 6042 | សំលៀកបំពាក់ការពារសុវត្ថិភាព | |
| | | 6043 | មេដាយ (គ្រឿងឥស្សរិយយស) | |
| | | 6048 | ផ្សេងៗ | |
| | 605 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | |
| | | 6051 | សម្ភារៈ និងបរិក្ខារ | |
| | | 6052 | សង្ហារឹម | |
| | | 6053 | សម្ភារៈប្រើប្រាស់ | |
| | | 6054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | |
| | | 6058 | ផ្សេងៗ | |
| | 606 | | ថាមពល និងទឹក | |
| | | 6061 | អគ្គិសនី | |
| | | 6062 | ទឹក | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| | | 6068 | ផ្សេងៗ | |
| | 608 | | សម្ភារៈផ្គត់ផ្គង់ផ្សេងៗ | |
| 61 | | | សេវាខាងក្រៅ | |
| | 611 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | |
| | 612 | | ការជួលមធ្យោបាយដឹកជញ្ជូន | |
| | 613 | | ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម ) | |
| | 614 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក | |
| | 615 | | ការថែទាំ និងជួសជុល | |
| | | 6151 | ការថែទាំដីធ្លី សួនច្បារ និងរៀបជាជួរ | |
| | | 6152 | ការថែទាំ ទីផ្សារ សត្តឃាតដ្ឋាន និងអគារសាធារណៈ | |
| | | 6153 | ការថែទាំជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រព័ន្ធលូ | |
| | | 6154 | ការថែទាំបណ្តាញផ្សេងៗ | |
| | | 6155 | ការថែទាំនិងជួសជុលឧបករណ៍ សម្ភារៈការិយាល័យ សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ | |
| | | 6156 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | |
| | | 6157 | ការថែទាំ និងជួសជុលសម្ភារៈឧបករណ៍បច្ចេកទេស | |
| | 616 | | សោហ៊ុយធានារ៉ាប់រង | |
| | 617 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | |
| | | 6171 | សោហ៊ុយសិក្សាពិសោធន៍ | |
| | | 6172 | សោហ៊ុយនៃការប្រើប្រាស់សេវា | |
| | | 6173 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | |
| | | 6174 | សំណងផ្នែកស៊ីវិល | |
| | 618 | | សោហ៊ុយដឹកជញ្ជូន | |
| | | 6181 | សម្ភារៈនិងទំនិញ | |
| 62 | | | សេវាខាងក្រៅផ្សេងៗ | |
| | 621 | | បុគ្គលិកខាងក្រៅ | |
| | | 6211 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | |
| | | 6212 | ភ្នាក់ងារបរទេសជាប់កិច្ចសន្យា | |
| | | 6213 | បុគ្គលិកសមូហភាពសាធារណៈផ្សេងៗ | |
| | 622 | | ទំនាក់ទំនងសាធារណៈ និងការផ្សព្វផ្សាយ | |
| | | 6221 | សោហ៊ុយទទួលភ្ញៀវជាតិ | |
| | | 6222 | សោហ៊ុយទទួលភ្ញៀវបរទេស | |
| | | 6223 | ប្រជុំ-សិក្ខាសាលា និងសន្និសីទ | |
| | | 6224 | សោហ៊ុយពិធីបុណ្យ | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| | | | . បុណ្យជាតិ និងបុណ្យប្រពៃណីយ៍ | |
| | | | . បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ | |
| | | | . បុណ្យរុក្ខទិវា | |
| | | | . បុណ្យផ្សេងៗទៀត | |
| | | 6225 | ការទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស | |
| | | 6226 | សោហ៊ុយសម្រាប់ការតាំងពិពណ៌នៅក្នុងនិងក្រៅប្រទេស | |
| | | 6227 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | |
| | 623 | | សោហ៊ុយជាវសារព័ត៌មាន និងឯកសារ | |
| | 624 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | |
| | | 6241 | សោហ៊ុយដឹកជញ្ជូន | |
| | | 6242 | សោហ៊ុយបេសកកម្ម | |
| | | 6243 | សោហ៊ុយស្នាក់នៅ | |
| | 625 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | |
| | | 6251 | សោហ៊ុយដឹកជញ្ជូន | |
| | | 6252 | សោហ៊ុយបេសកកម្ម | |
| | | 6253 | សោហ៊ុយស្នាក់នៅ | |
| | 626 | | សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទគេឡិច និងទូរសារប្រៃណីយ៍ | |
| | | 6261 | សោហ៊ុយប្រៃសណីយ៍ | |
| | | 6262 | សោហ៊ុយទូរគមនាគមន៍ | |
| | 627 | | សោហ៊ុយធនាគារ | |
| | 628 | | សោហ៊ុយផ្សេងៗ | |
| 64 | | | បន្ទុកបុគ្គលិក | |
| | 641 | | លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ | |
| | | 6411 | ប្រាក់បំណាច់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | |
| | | 6412 | ប្រាក់បំណាច់អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | |
| | | 6413 | លាភការទីប្រឹក្សា | |
| | | 6414 | លាភការបេសកជន | |
| | 642 | | លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | |
| | | 6421 | បៀវត្សមូលដ្ឋាន | |
| | | 6422 | ប្រាក់បំណាច់មុខងារ | |
| | | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | |
| | | 6424 | ប្រាក់បំណាច់តំបន់ | |
| | | 6425 | ប្រាក់បំណាច់ទទួលខុសត្រូវ | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| | | 6426 | ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព | |
| | 643 | | រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត | |
| | | 6431 | កន្សោមអាទិភាព | |
| | | 6432 | ប្រាក់បំណាច់សម្រាប់ប្រឡង-ប្រឡងប្រជែង | |
| | | 6433 | រង្វាន់ | |
| | | 6434 | ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ | |
| | | 6438 | ផ្សេងៗ | |
| | 644 | | លាភការនិងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត | |
| | | 6441 | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | |
| | | 6442 | លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ | |
| | | 6443 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | |
| | | 6444 | លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត | |
| | | 6445 | ប្រាក់ឧបត្ថម្ភភូមិ | |
| | 645 | | ប្រាក់វិភាជន៍សង្គម | |
| | | 6451 | ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ | |
| | | | . កូនមានអាយុតិចជាង១៥ឆ្នាំ | |
| | | | . កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ | |
| | | | . ប្រាក់បំណាច់អ្នកក្នុងបន្ទុក | |
| | | 6452 | មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសម្រាលកូន | |
| | | 6453 | មរណៈភាព | |
| | | 6454 | ឧបត្ថម្ភនិវត្តជន | |
| | | 6455 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | |
| | | 6456 | គ្រោះថ្នាក់ការងារ និងទុព្វលភាព | |
| | | 6457 | ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ | |
| | | 6458 | ផ្សេងៗ | |
| **ប្រភេទទី ២: បន្ទុកហិរញ្ញវត្ថុ** | | | | |
| 66 | | | បន្ទុកហិរញ្ញវត្ថុ | |
| **ប្រភេទទី ៣: អន្តរាគមន៍សាធារណៈ** | | | | |
| 65 | | | ឧបត្ថម្ភកធន និងជំនួយសង្គម | |
| | 651 | | ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី | |
| | | 6511 | ឧបត្ថម្ភកធនដល់ក្រុង ស្រុក ខណ្ឌ | |
| | | 6512 | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ | |
| | | 6513 | ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| | 652 | | ជំនួយសង្គម និងប្រាក់វិភាជន៍ | |
| | | 6521 | ជំនួយដល់ប្រជាជនក្រីក្រសម្រាកពេទ្យ | |
| | | 6522 | ជួយជនរងគ្រោះដោយធម្មជាតិ | |
| | | 6528 | ចំណាយសង្គមផ្សេងៗទៀត | |
| | 653 | | ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គម និងវប្បធម៌ | |
| | | 6531 | ឧបត្ថម្ភមណ្ឌលកុមារកំព្រា | |
| | | 6532 | ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌ | |
| | | 6533 | ឧបត្ថម្ភកាកបាទក្រហម | |
| | | 6534 | ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ | |
| | 654 | | ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | |
| | 656 | | វិភាគទានដល់អង្គការអន្តរជាតិនានា | |
| | | 6568 | អង្គការអន្តរជាតិផ្សេងៗទៀត | |
| **ប្រភេទទី ៤: ចំណាយផ្សេងៗ** | | | | |
| 63 | | | ពន្ធ និងអាករ | |
| | 631 | | លតាប័ត្រ | |
| | 633 | | បន្ទុកពន្ធប្រថាប់ត្រា | |
| ខ. **ក្រុមទី ២: ចំណាយតាមដីកានិងចំណាយមិនបានគ្រោងទុក**(ប្រ.៥+ប្រ.៦) | | | | |
| **ប្រភេទទី ៥: ចំណាយតាមដីកា** ( **មិនឆ្លងសាច់ប្រាក់** ) | | | | |
| 67 | | | បន្ទុកពិសេស | |
| | 671 | | ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន | |
| | 675 | | តម្លៃគណនេយ្យនៃចំណែកសកម្មបានលក់(តម្លៃនៅសល់) | |
| 68 | | | ទាយជ្ជទានឲ្យដល់រំលស់អចលកម្ម | |
| | 681 | | ទាយជ្ជទានឲ្យដល់រំលស់អចលកម្មអរូបី | |
| | 682 | | ទាយជ្ជទានឲ្យដល់រំលស់អចលកម្មរូបី | |
| **ប្រភេទទី ៦: ចំណាយមិនបានគ្រោងទុក** | | | | |
| 09 | | | ចំណាយមិនបានគ្រោងទុក | |
| II - **សរុបចំណាយជាមូលធន** ( **ក** + **ខ** ) | | | | |
| ក. **ក្រុមទី ១: ចំណាយពិត** ( ប្រ. ១ + ប្រ. ២ ) | | | | |
| **ប្រភេទទី ១: អចលកម្ម** | | | | |
| 20 | | | អចលកម្មអរូបី | |
| | 203 | | សោហ៊ុយសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍ | |
| | 205 | | ប្រកាសនីយប័ត្រ អាជ្ញាប័ណ្ណ និងសិទ្ធិប្រហាក់ប្រហែល | |
| 21 | | | អចលកម្មរូបី | |

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ផ្សេងៗ |
|---|---|---|---|---|
| | 211 | | ដីធ្លី និងធនធានធម្មជាតិ | |
| | 212 | | ការរៀបចំកែលំអដីធ្លី | |
| | 213 | | សំណង់ | |
| | | 2131 | អគារ | |
| | | 2132 | ការរៀបចំកែលំអអគារ | |
| | | 2138 | សំណង់ផ្សេងៗទៀត | |
| | 214 | | ហេដ្ឋារចនាសម្ព័ន្ធ | |
| | | 2141 | បណ្តាញបង្ហូរទឹក និងអនាម័យ | |
| | | 2142 | បណ្តាញអគ្គិសនី | |
| | | 2143 | បណ្តាញធារាសាស្ត្រ | |
| | | 2144 | បណ្តាញផ្លូវថ្នល់ និងស្ពាន | |
| | 215 | | ឋបនកម្មបច្ចេកទេស សម្ភារៈ និងហត្ថូបករណ៍ | |
| | | 2151 | ឋបនកម្មបច្ចេកទេស | |
| | | 2152 | សម្ភារៈ | |
| | | 2153 | គ្រឿងឧបករណ៍ (ហត្ថូបករណ៍) | |
| | 218 | | អចលកម្មរូបីផ្សេងទៀត | |
| | | 2181 | សម្ភារៈឧបករណ៍ដឹកជញ្ជូន | |
| | | 2182 | សម្ភារៈឧបករណ៍ការិយាល័យ | |
| | | 2183 | សម្ភារៈព័ត៌មានវិទ្យា និងទូរគមនាគមន៍ | |
| | | 2184 | សង្ហារឹម | |
| | | 2188 | ផ្សេងៗ | |
| **ខ. ក្រុមទី ២: ចំណាយតាមដីកា** | | | | |
| **ប្រភេទទី ២: ចំណាយតាមដីកា** | | | | |